សន្លឹកព័ត៌មានស្ដីពីថ្នាំវ៉ាក់សាំង

# ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B

## *អ្វីដែលអ្នកត្រូវដឹង*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សន្លឹកព័ត៌មានស្ដីពីថ្នាំវ៉ាក់សាំងជាច្រើនមានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ សូមចូលទៅ www.immunize.org/vis

## 1 តើជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺអ្វី?

ជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺធ្ងន់ធ្ងរដែលប៉ះពាលដល់ថ្លើម។ ជំងឺនេះបង្កឡើងដោយមេរោគជំងឺរលាកថ្លើមប្រភេទ B។

- ក្នុងឆ្នាំ 2009 មានមនុស្សប្រហែល 38,000 នាក់បានឆ្លងជំងឺរលាកថ្លើមប្រភេទ B។
- មួយឆ្នាំៗ នៅសហរដ្ឋអាមេរិក មនុស្សប្រហែល 2,000 ទៅ 4,000 នាក់ស្លាប់បាត់បង់ជីវិត ដោយសារជំងឺក្រិនថ្លើម ឬជំងឺមហារីកថ្លើម ដែលបង្កឡើងដោយជំងឺរលាកថ្លើមប្រភេទ B។

ជំងឺរលាកថ្លើមប្រភេទ B អាចបង្ក៖

**ជំងឺធ្ងន់ធ្ងរ (រយៈពេលខ្លី)**។ ជំងឺនេះអាចបណ្ដាលឲ្យ៖

- បាត់បង់ចំណង់អាហារ
- រោគរាគរូស និងក្អួត
- នឿយហត់
- ជំងឺខាន់លឿង (ស្បែក ឬភ្នែកព៌ណលឿង)
- ឈឺចុកចាប់សាច់ដុំ សន្លាក់ និងក្រពះ

ជំងឺធ្ងន់ធ្ងរដែលមានរោគសញ្ញាកើតឡើងជាទូទៅក្នុងចំណោមមនុស្សពេញវ័យ។ ជាធម្មតា កុមារដែលឆ្លងជំងឺរលាកថ្លើមប្រភេទ B នេះ ពុំបង្ហាញរោគសញ្ញាទេ។

**ជំងឺរ៉ាំរ៉ៃ (រយៈពេលវែង)**។ មនុស្សមួយចំនួនវិវត្តទៅកើតជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ។ មនុស្សភាគច្រើនគ្មានរោគសញ្ញាទេ ប៉ុន្តែជំងឺនៅតែធ្ងន់ធ្ងរ ហើយអាចបណ្ដាលឲ្យ៖

- ខូចថ្លើម (ជំងឺក្រិនថ្លើម)
- ជំងឺមហារីកថ្លើម
- ស្លាប់បាត់បង់ជីវិត

ជំងឺរ៉ាំរ៉ៃកើតឡើងជាទូទៅក្នុងចំណោមទារក និងកុមារជាងក្នុងចំណោមមនុស្សពេញវ័យ។ មនុស្សដែលមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃអាចចម្លងមេរោគជំងឺរលាកថ្លើមប្រភេទ B ទៅអ្នកដទៃទៀត បើទោះបីជាពួកគេហាក់បីដូចជាមិនឈឺ ឬគ្មានអារម្មណ៍ឈឺក៏ដោយ។ មនុស្សដល់ទៅ 1.4 លាននាក់នៅសហរដ្ឋអាមេរិក អាចមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ។

មេរោគជំងឺរលាកថ្លើមប្រភេទ B អាចចម្លងបានយ៉ាងងាយស្រួលតាមរយៈការប៉ះពាល់ឈាម ឬវត្ថុរាវដទៃទៀតពីខ្លួនប្រាណរបស់អ្នកផ្ទុកមេរោគនេះ។ មនុស្សក៏អាចឆ្លងជំងឺនេះផងដែរដោយសារតែការប៉ះពាល់វត្ថុកខ្វក់ ដែលមេរោគជំងឺនេះអាចមានជីវិតរហូតដល់ទៅ 7 ថ្ងៃ។

- ទារក ដែលមានម្ដាយកើតជំងឺរលាកថ្លើមប្រភេទនេះ អាចឆ្លងមេរោគជំងឺនេះនៅពេលកើត។
- កុមារ យុវជន និងមនុស្សពេញវ័យអាចឆ្លងមេរោគជំងឺរលាកថ្លើមប្រភេទ B តាមរយៈ៖
  - ការប៉ះពាល់ឈាម និងវត្ថុរាវនៃខ្លួនប្រាណ តាមរយៈកន្លែងដាច់ស្បែក ដូចជាកន្លែងខាំ កន្លែងមុត ឬដំបៅ
  - ប៉ះពាល់វត្ថុដែលប្រឡាក់ឈាម ឬវត្ថុរាវនៃខ្លួនប្រាណ ដូចជា (ច្រាស់ដុសធ្មេញ ឡាម ឬឧបករណ៍តាមដាន និងព្យាបាលជំងឺទឹកនោមផ្អែម
  - រួមភេទដោយគ្មានការការពារជាមួយនឹងអ្នកដែលមានជំងឺនេះ
  - ប្រើប្រាស់ម្ជុលចាក់ថ្នាំញៀនរួមគ្នា
  - មុតម្ជុលដែលបានប្រើរួច។

## 2 ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B៖ ហេតុអ្វីត្រូវទទួលថ្នាំវ៉ាក់សាំង?

ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B អាចបង្ការជំងឺរលាកថ្លើមប្រភេទ B និងផលវិបាកធ្ងន់ធ្ងរនៃជំងឺរលាកថ្លើមប្រភេទ B នេះ ដែលរាប់បញ្ចូលទាំងជំងឺមហារីក និងជំងឺក្រិនថ្លើម។

ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B អាចចាក់តែឯង ឬក្នុងម្ជុលតែមួយដែលមានថ្នាំវ៉ាក់សាំងដទៃផ្សេងទៀត។

ការចាក់ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ជាធម្មតា ត្រូវបានណែនាំសម្រាប់មនុស្សពេញវ័យ និងកុមារមួយចំនួននៅសហរដ្ឋអាមេរិក នៅឆ្នាំ 1982 និងកុមារទាំងអស់នៅឆ្នាំ 1991។ ចាប់តាំងពីឆ្នាំ 1990 មក ករណីឆ្លងជំងឺរលាកថ្លើមប្រភេទ B ថ្មីៗ ក្នុងចំណោមកុមារ និងយុវជន បានធ្លាក់ចុះជាង 95% — និង 75% ចំពោះក្រុមអាយុដទៃទៀត។

ការចាក់ថ្នាំវ៉ាក់សាំងផ្ដល់នូវការការពាររយៈពេលវែងចំពោះជំងឺរលាកថ្លើមប្រភេទ B ដែលការការពារនេះអាចមានរយៈពេលមួយជីវិត។

## 3 តើអ្នកណាគួរទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ហើយនៅពេលណា?

### កុមារ និងយុវជន

- ជាធម្មតា ទារកទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ចំនួន 3 ដូស៖

  | | |
  |---|---|
  | ដូសទី 1៖ | ពេលកើត |
  | ដូសទី 2៖ | អាយុ 1-2 ខែ |
  | ដូសទី 3៖: | អាយុ 6-18 ខែ |

  ឧទាហរណ៍ ទារកមួយចំនួនអាចទទួលថ្នាំវ៉ាក់សាំងចំនួន 4 ដូស ប្រសិនបើគេប្រើប្រាស់ថ្នាំវ៉ាក់សាំងរួមផ្សំដែលមានថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B។ (ថ្នាំវ៉ាក់សាំងរួមផ្សំនេះគឺជាថ្នាំវ៉ាក់សាំងមួយម្ជុលដែលមានថ្នាំវ៉ាក់សាំងច្រើនប្រភេទ) ការចាក់ដូសបន្ថែមពុំបង្កគ្រោះថ្នាក់ទេ។

- ជនណាដល់វ័យ 18 ឆ្នាំ ដែលមិនទាន់ចាក់ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B នៅពេលក្មេងនោះ គួរតែចាក់ថ្នាំវ៉ាក់សាំងនេះផងដែរ។

### មនុស្សពេញវ័យ

- មនុស្សពេញវ័យទាំងអស់ ដែលមិនបានចាក់ថ្នាំវ៉ាក់សាំង និងដែលមានហានិភ័យឆ្លងជំងឺរលាកថ្លើមប្រភេទ B គួរចាក់ថ្នាំវ៉ាក់សាំងនេះ។ នេះរួមបញ្ចូល៖
  - ដៃគូរួមភេទរបស់អ្នកដែលមានជំងឺរលាកថ្លើមប្រភេទ B
  - បុរសដែលរួមភេទជាមួយនឹងបុរសដូចគ្នា
  - អ្នកដែលចាក់ថ្នាំញៀនតាមផ្លូវ
  - អ្នកដែលមានដៃគូរួមភេទច្រើនជាងម្នាក់
  - អ្នកដែលមានជំងឺតម្រងនោម ឬថ្លើមរ៉ាំរ៉ៃ
  - អ្នកអាយុក្រោម 60 ឆ្នាំដែលមានជំងឺទឹកនោមផ្អែម
  - អ្នកមានការងារ ដែលប៉ះពាល់ឈាមមនុស្ស ឬវត្ថុរាវនៃខ្លួនប្រាណដទៃទៀត

U.S. Department of Health and Human Services
Centers for Disease Control and Prevention

- ក្រុមគ្រួសាររបស់អ្នកដែលមានជំងឺរលាកថ្លើមប្រភេទ B
- អ្នកស្នាក់នៅ និងបុគ្គលក្នុងគ្រឹះស្ថានអ្នកពិការខាងការលូតលាស់
- អ្នកជំងឺលាងឈាមសម្អាតតម្រងនោម
- អ្នកដែលធ្វើដំណើរទៅកាន់ប្រទេសដែលមានជំងឺរលាកថ្លើមប្រភេទ B ជាទូទៅ
- អ្នកផ្ទុកមេរោគអេដស៍

• អ្នកដទៃទៀតអាចត្រូវបានលើកទឹកចិត្តដោយវេជ្ជបណ្ឌិតរបស់ពួកគេឲ្យទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ឧទាហរណ៍ មនុស្សពេញវ័យអាយុ 60 ឆ្នាំនិងលើសពី 60 ឆ្នាំដែលមានជំងឺទឹកនោមផ្អែម។ អ្នកផ្សេងទៀតដែលចង់ទទួលបានការការពារប្រឆាំងនឹងជំងឺរលាកថ្លើមប្រភេទ B អាចចាក់ថ្នាំវ៉ាក់សាំងនេះបាន។

• ស្ត្រីមានផ្ទៃពោះ ដែលមានហានិភ័យដោយសារមូលហេតុណាមួយដែលចែងខាងលើ គួរចាក់ថ្នាំវ៉ាក់សាំងនេះ។ ស្ត្រីមានផ្ទៃពោះដទៃទៀត ដែលចង់បានការការពារប្រឆាំងនឹងជំងឺរលាកថ្លើមប្រភេទ B អាចចាក់ថ្នាំវ៉ាក់សាំងនេះបាន។

មនុស្សពេញវ័យដែលកំពុងទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B គួរទទួលថ្នាំវ៉ាក់សាំងនេះចំនួន 3 ដូស ដោយដូសទី 2 ត្រូវចាក់ 4 សប្តាហ៍បន្ទាប់ពីដូសទី 1 ហើយដូសទី 3 គឺ 5 ខែបន្ទាប់ពីដូសទី 2។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចប្រាប់លោកអ្នកអំពីកាលវិភាគផ្សេងទៀតសម្រាប់ការចាក់ដូសថ្នាំវ៉ាក់សាំង ដែលអាចប្រើក្នុងស្ថានការណ៍មួយចំនួន។

## 4 តើអ្នកណាមិនគួរទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B

• ជនណាដែលមានប្រតិកម្មអាឡាក់ស៊ីនឹងមេដំបែ (yeast) ឬធាតុផ្សំដទៃទៀតនៃថ្នាំវ៉ាក់សាំង ដែលគំរាមដល់អាយុជីវិត មិនគួរទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ទេ។ សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើលោកអ្នកមានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរណាមួយនោះ។

• ជនណាដែលមានប្រតិកម្មអាឡាក់ស៊ីនឹងដូសមុននៃថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ដែលគំរាមដល់អាយុជីវិតនោះ មិនគួរទទួលដូសមួយទៀតនៃថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ទេ។

• ជនណាដែលឈឺធ្ងន់ល្មម ឬធ្ងន់ធ្ងរ នៅពេលត្រូវចាក់ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ប្រហែលគួររង់ចាំសិន រហូតទាល់តែគេជាសះស្បើយ ទើបចាក់ថ្នាំវ៉ាក់សាំងនេះបាន។

វេជ្ជបណ្ឌិតរបស់លោកអ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់លោកអ្នកអំពីការប្រយ័ត្នជាមុនទាំងនេះ។

សម្គាល់៖ គេអាចស្នើឲ្យលោកអ្នករង់ចាំ 28 ថ្ងៃ មុននឹងបរិច្ចាគឈាម បន្ទាប់ពីបានទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B។ នេះគឺដោយសារថា តេស្តពិនិត្យអាចភ័ន្តច្រឡំថ្នាំវ៉ាក់សាំងក្នុងឈាម (ដែលមិនមែនជាជំងឺ) ថាជាជំងឺរលាកថ្លើមប្រភេទ B។

## 5 តើមានហានិភ័យអ្វីខ្លះដោយសារថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B?

ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B គឺជាថ្នាំវ៉ាក់សាំងដែលមានសុវត្ថិភាពណាស់។ មនុស្សភាគច្រើនគ្មានបញ្ហាជាមួយនឹងថ្នាំវ៉ាក់សាំងនេះទេ។

ថ្នាំវ៉ាក់សាំងនេះពុំមានមេរោគចម្លងទេ ហើយមិនអាចបណ្តាលឲ្យកើតជំងឺរលាកថ្លើមប្រភេទ B ឡើយ។

បញ្ហាស្រាលមួយចំនួនត្រូវបានរាយការណ៍ ដូចជា៖

• ដំបៅនៅកន្លែងចាក់ថ្នាំវ៉ាក់សាំង (មនុស្សប្រហែលម្នាក់ក្នុងចំណោម 4 នាក់)
• សីតុណ្ហភាព 99.9°F ឬខ្ពស់ជាងនេះ (មនុស្សប្រហែលម្នាក់ក្នុងចំណោម 15 នាក់)

បញ្ហាធ្ងន់ធ្ងរគឺកម្រណាស់។ ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរត្រូវបានគេជឿជាក់ថាកើតឡើងប្រហែលម្តងក្នុងចំណោម 1.1 លានដូស។

ថ្នាំវ៉ាក់សាំង គឺដូចឱសថផងដែរ គឺអាចបង្កប្រតិកម្មធ្ងន់ធ្ងរ។ ប៉ុន្តែ ហានិភ័យដែលថ្នាំវ៉ាក់សាំងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតនោះ គឺមានកម្រិតតិចតួចបំផុត។ មនុស្សជាង 100 លាននាក់នៅសហរដ្ឋអាមេរិកបានចាក់វ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B។

## 6 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរ?

### តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?

• សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬការប្តូរឥរិយាបថ។

សញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ អាចរួមបញ្ចូលកន្ទួល ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ បញ្ហាទាំងនេះនឹងចាប់ផ្តើមកើតឡើងរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង។

### តើខ្ញុំគួរធ្វើអ្វីខ្លះ?

• ប្រសិនបើលោកអ្នកគិតថា វាគឺជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬយកអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនអញ្ចឹងទេ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក។

• បន្ទាប់មក ប្រតិកម្មគួររាយការណ៍ទៅប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (Vaccine Adverse Event Reporting System (VAERS))។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈវេបសាយ VAERS នៅ **www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក **1-800-822-7967**។

*VAERS គឺសម្រាប់តែការរាយការណ៍ប្រតិកម្មផ្សេងៗប៉ុណ្ណោះ។ ប្រព័ន្ធនេះពុំផ្តល់ដំបូន្មានវេជ្ជសាស្ត្រទេ។*

## 7 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program)

កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program (VICP)) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយ អាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក**1-800-338-2382** ឬចូលទៅវេបសាយ VICP នៅ **www.hrsa.gov/vaccinecompensation**។

## 8 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

• សួរវេជ្ជបណ្ឌិតរបស់លោកអ្នក។ 1-888-767-4687
• ទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
• ទាក់ទងមជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺឆ្លង (CDC):
  - ទូរស័ព្ទមកលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅវេបសាយ CDC នៅ **www.cdc.gov/vaccines**

Vaccine Information Statement (Interim)

# Hepatitis B Vaccine

2/2/2012 Khmer

42 U.S.C. § 300aa-26

Office Use Only

DCH-0450CA AUTH: P. H. S., Act 42, Sect. 2126.

Translation provided by the Immunization Action Coalition

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណគ្រឹមត្រូវ. ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត. ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។